UNDP

Empowered lives.
Resilient nations.

# ព្រឹត្តិបត្រព័ត៌មាន

លេខ ៤៣
ខែ កញ្ញា ឆ្នាំ ២០១៤

*យូអិនឌីភី ធ្វើដៃគូជាមួយប្រជាជនគ្រប់ស្រទាប់សង្គមក្នុងការជួយប្រជាជាតិឲ្យមានភាពស្វិតស្វាញទប់ទល់នឹងវិបត្តិ ជំរុញ និងរក្សាចីរភាពកំណើន សំដៅលើកស្ទួយគុណភាពនៃជីវភាពសម្រាប់ទាំងអស់គ្នា។ យើងមានវត្តមានក្នុងប្រទេសនិងដែនដីជាង ១៧០ ហើយយើងប្រើប្រាស់ទស្សនវិស័យសកល និងក្នុងស្រុក ដើម្បីជួយប្រជាជន និងប្រជាជាតិកសាងជីវភាពឲ្យបានកាន់តែប្រសើរ និងរឹងមាំថែមទៀត។*

## ពីចម្ការមីនមកជាច្បារចំណាំ

**ប៉ៃលិន** - អស់រយៈពេលច្រើនជាង មួយទសវត្សរ៍មកហើយអ្នកស្រី ឃិត សារិន និងអ្នកជិតខាងរបស់គាត់បានរស់នៅលើដីមួយកន្លែង ដែលគេសង្ស័យថាមានគ្រាប់មីនក្នុងខេត្តប៉ៃលិន ។ ពួកគេសម្រេចប្រថុយរស់នៅទីនេះ ដោយពុំមានធនធានគ្រប់គ្រាន់សម្រាប់រើទីតាំងទៅនៅក្នុងតំបន់ដែលមានសុវត្ថិភាព។ នៅថ្ងៃមួយ មីនមួយគ្រាប់ផ្ទុះក្នុងច្បារនៅក្រោយផ្ទះគាត់ ដែលធ្វើឲ្យងាប់គោមួយក្បាល ហើយអ្នកស្រី ឃិត សារិន ក៏បានទាក់ទងអាជ្ញាធរមូលដ្ឋានឲ្យជួយដោះស្រាយបញ្ហានេះ។

នាងពោលថា “ពួកអ្នកដោះមីនបានរកឃើញគ្រាប់មីនប្រឆាំងមនុស្ស ១៩គ្រាប់នៅក្រោយផ្ទះខ្ញុំ និងនៅជុំវិញផ្ទះរបស់អ្នកជិតខាងខ្ញុំ។” តាមរយៈគម្រោង “សំអាតដើម្បីលទ្ធផល” ផ្ទៃដីប្រមាណ ៦ គ.ម២ នៅក្នុងភូមិអូរប្រាកើត ត្រូវបានបោសសំអាត និងបានរំដោះពីគ្រាប់មីននៅឆ្នាំ ២០១៣។ យ៉ាងហោចណាស់ប្រជាជនចំនួន ៧គ្រួសារនៅក្នុងភូមិនេះ ឥឡូវកំពុងរស់នៅដោយសុវត្ថិភាព និងប្រកបរបរចិញ្ចឹមជីវិតដោយសុខសាន្ត។

បន្ទាប់មក នាង ឃិត សារិន បានចាប់ផ្ដើមដាំដំណាំហូបផ្លែ ដូចជា មៀន ស្រកានាគ និងចេកនៅលើផ្ទៃដីទំហំ ២៤ម x ១០៧ម នៅក្រោយផ្ទះរបស់គាត់ បន្ថែមលើដើមខ្នុរ និងដូង។ គាត់លក់ផលដំណាំភាគច្រើននៅទីផ្សារ និងផលដែលនៅសល់ពីនេះសម្រាប់បរិភោគក្នុងគ្រួសារ ឬ ចែករំលែកជាមួយអ្នកជិត។ ស្ត្រីអាយុ ៥៩ឆ្នាំរូបនេះដែលមានកូនបួននាក់ មានសង្ឃឹមថា ផលចំណេញពីឈើហូបផ្លែ នឹងបន្ថែមពីលើផលចំណេញរបស់គាត់ចំនួន ៧០០ដុល្លា ពីដំណាំដំឡូងមីនៅក្បែរផ្ទះផងដែរ។

នៅជាប់ផ្ទះគាត់ កសិករ នូ ជាតា និងភរិយាឈ្មោះ វន សុគន្ធ បានឃើញគ្រាប់ទំរមួយគ្រឿងជាន់គ្រាប់មីន

តទៅទំព័រទី ២

### មាតិកា

ជីវភាពអ្នកឃុំចំបក់កាន់តែប្រសើរដោយសារប្រព័ន្ធទឹកស្អាត ........................................ ២
សន្ទស្សន៍អភិវឌ្ឍន៍មនុស្សកម្ពុជាបន្តកើនឡើង.. ៣
កិច្ចគាំពារសង្គមជាគន្លឹះក្នុងការកាត់បន្ថយភាពងាយរងគ្រោះនៃជនក្រីក្រ............................ ៣
បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការនៅមូលដ្ឋាន...................៤
អ្នកស្ម័គ្រចិត្តសហប្រជាជាតិរៀបចំវេទិកាជាតិលើកទី ៤ ស្តីពីភាពជាអ្នកស្ម័គ្រចិត្ត..............៤

## នៅឃុំត្រពាំងចាន់ ស្ត្រីនាំមុខក្នុងកិច្ចការពារព្រៃឈើ



Photo: UNDP Cambodia

*អ្នកស្រី សាំង ម៉ៅ អាយុ ៦១ ឆ្នាំ រូបខាងមុខ និងអ្នកជិតខាងរបស់គាត់ម្នាក់ ប្រមូលអនុផលព្រៃឈើយកទៅធ្វើថ្នាំបុរាណពីសហគមន៍ព្រៃការពារនៅឃុំត្រពាំងចាន់ ក្នុងខេត្តកំពង់ឆ្នាំង។*

**កំពង់ឆ្នាំង** - ”បើយើងមានព្រៃឈើ យើងមានជីវិត” ស្ត្រីអាយុ ៦១ ឆ្នាំ ឈ្មោះ សាំង ម៉ៅ រម្លឹកឡើងវិញអំពីពាក្យស្លោករបស់ជាតិដែលជាសក្ខីកម្មនៃកំណើនការយល់ដឹង និងការពាក់ព័ន្ធរបស់ស្ត្រីក្នុងកិច្ចការពារព្រៃឈើ។ សាំង ម៉ៅ ដែលជាអនុប្រធានគណៈកម្មការគ្រប់គ្រងព្រៃសហគមន៍ក្នុងឃុំ ស្ថិតក្នុងចំណោមស្ត្រីជាច្រើនរយនាក់ដែលបានទទួលការបណ្ដុះបណ្ដាល តាមរយៈគម្រោងគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពរបស់យូអិនឌីភី។ កិច្ចផ្ដួចផ្ដើមនេះដែលទទួលថវិកាតាមរយៈ មូលនិធិបរិស្ថានពិភពលោក បានគាំទ្ររដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តសកម្មភាពជាអាទិភាពរបស់ខ្លួននៅក្នុងកម្មវិធីគ្រប់គ្រងព្រៃឈើជាតិ។

ប្រជាជនកម្ពុជាប្រមាណ៨៥ ភាគរយ ពឹងផ្អែកលើកសិផលនិងផលពីព្រៃឈើ សម្រាប់ការចិញ្ចឹមជីវិតជាបឋមរបស់ខ្លួន។ ធនធានព្រៃឈើ រួមចំណែកពី៣០-៤២ ភាគរយនៃប្រាក់ចំណូលសរុបរបស់គ្រួសារនៅតាមជនបទ។ តាមអត្រានេះ មានការប៉ាន់ស្មានថា កម្ពុជាត្រូវស្តារផ្ទៃដីព្រៃរេចរឹលប្រមាណ ២,៦លានហិកតាឡើងវិញ។

អ្នកស្រី សាំង ម៉ៅ ពោលថា “កាលពីមុន ខ្ញុំមិនដឹងថាហេតុអ្វីការពារព្រៃឈើមានសារៈសំខាន់ឡើយ។” អ្នកស្រីពោលថា “ព្រៃឈើផ្តល់ជាមូលដ្ឋានសម្រាប់ការចិញ្ចឹមជីវិតរបស់យើង និងការពារយើងពីទឹកជំនន់។ ឥឡូវនេះ ខ្ញុំដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់យើង។ ការធ្វើបែបនេះ គឺដើម្បីមនុស្សជំនាន់ក្រោយ□។

ក្នុងឃុំត្រពាំងចាន់ ខេត្តកំពង់ឆ្នាំង ដែលជាកន្លែងរស់នៅរបស់អ្នកស្រី សាំង ម៉ៅ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើចំនួន១៤ ធ្វើការល្បាតតំបន់សហគមន៍ តំបន់ការពារធម្មជាតិ ដាំដើមឈើ និងសម្អាតព្រៃឈើមិនឲ្យមានសម្រាម។ យូអិនឌីភី និងដៃគូរបស់ខ្លួនបានចាត់ចែងវគ្គបណ្ដុះបណ្ដាលអំពីជំហានទាំងប្រាំបីនៃការគ្រប់គ្រងសហគមន៍ព្រៃឈើ ដែលរួមទាំង ការកសាងផែនទីតាមបែបផែននៃការចូលរួម ការធ្វើសារពើភណ្ឌព្រៃឈើ និងការបង្កើតផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ។ នៅឆ្នាំ ២០១៣ វគ្គបណ្ដុះបណ្ដាលតាមមូលដ្ឋានចំនួន ៩១លើក ត្រូវបានរៀបចំឡើង សម្រាប់សមាជិកគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ សមាជិកក្រុមប្រឹក្សាឃុំ និងប្រធានភូមិ សរុបចំនួន ១.៨៥៤នាក់ ក្នុងនោះស្ត្រី ៥៣៧នាក់។

លោក ជា សុង អនុប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើក្នុងឃុំ ១៨៥K បានពោលថា “ព្រៃឈើនេះជារបស់យើង។ យើងកៀងគរសហគមន៍ឲ្យចូលរួមដើម្បីយើងអាចការពារព្រៃនេះជាមួយគ្នាបាន”។

ប្រការសំខាន់ជាងនេះទៀតគឺគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ បាននិងកំពុងរៀបចំផែនការគ្រប់គ្រងសហគមន៍ព្រៃឈើរៀងៗខ្លួន តាមរយៈជំនួយបច្ចេកទេសពីគម្រោងនេះ។ មកទល់បច្ចុប្បន្ននេះ សហគមន៍ព្រៃឈើជាគោលដៅទាំង ៣០ បានជិតបញ្ចប់ដំណើរការកសាងផែនការគ្រប់គ្រងសហគមន៍ព្រៃឈើហើយ។

ក្រៅពីនេះ យូអិនឌីភី បាននិងកំពុងជម្រុញ និងផ្តល់ការបណ្ដុះបណ្ដាលជំនាញដល់ស្ត្រី នៅក្នុងការផលិតចង្ក្រានប្រសិទ្ធភាពថាមពលដែលកាត់បន្ថយការប្រើប្រាស់អុសបាន៣០ ភាគរយ។ ចង្ក្រាននាងកង្រី និងចង្ក្រាន

តទៅទំព័រទី ២

# ជីវភាពអ្នកឃុំចំបក់ កាន់តែប្រសើរដោយសារប្រព័ន្ធទឹកស្អាត

**កំពង់ស្ពឺ** - លោក សៅ បឿន ជាកសិករអាយុ ៣៨ឆ្នាំ នៅខេត្តកំពង់ស្ពឺ ធ្លាប់ដើរលើចម្ងាយផ្លូវ ៣គ.ម ជារៀងរាល់ថ្ងៃ ដើម្បីទៅដងទឹកសម្រាប់ផឹក ចំអិនអាហារ និងបោកគក់។ បច្ចុប្បន្ននេះ គាត់ទទួលបានទឹកស្អាត ចាប់តាំងពីគាត់តប្រព័ន្ធបំពង់ទឹកចូលមកក្នុងផ្ទះនៅក្នុងឆ្នាំ ២០១៣។

ឃុំចំបក់ ក្នុងខេត្តកំពង់ស្ពឺ មានប្រជាជនប្រមាណ ៦៣០គ្រួសារ ដែលឥឡូវនេះមានទឹកស្អាតប្រើប្រាស់ដល់ផ្ទះគ្រប់ពេលទាំងអស់។ អ្នកភូមិច្រើនជាង ៣.០០០នាក់ រហូតមកទល់ពេលថ្មីៗនេះ អាចត្រឹមតែងូតទឹកពីរថ្ងៃម្តង តែឥឡូវនេះពួកគេមានទឹកហើយ។

លោក សៅ បឿន បានរម្លឹកឡើងវិញថា “ជួនកាលយើងគ្មានទឹកគ្រប់គ្រាន់សម្រាប់ដាំស្លទេ ហើយយើងមិនទាំងហ៊ានបោកគក់សម្លៀកបំពាក់ និងលាងដៃញឹកញាប់ទេ ដល់អញ្ចឹងកូនក្មេងងាយឆ្លងមេរោគ ធ្លាក់ខ្លួនឈឺណាស់”។ តែឥឡូវនេះផ្ទះរបស់គាត់មានបង្គន់ចាក់ទឹក ដែលជាភាពចាំបាច់មួយពីមុនគាត់មិនអាចធ្វើបានឡើយដោយសារតែខ្វះទឹក។ នៅច្បារក្រោយផ្ទះ គាត់បានដាំបន្លែ និងជីកស្រះត្រីមួយ ដែលជាប្រភពស្បៀងអាហារនិងចំណូលសម្រាប់គ្រួសាររបស់គាត់។

ទាំងនេះមើលទៅដូចជារឿងសាមញ្ញមួយ ប៉ុន្តែគឺជាការប្រែប្រួលគួរឲ្យកត់សំគាល់ដែលកសិករនានានៅឃុំចំបក់កំពុងទទួលបានតាមរយៈគម្រោងដែលគាំទ្រដោយយូអិនឌីភី ក្នុងការជួយលើកកំពស់របរចិញ្ចឹមជីវិត។ កម្មវិធីបន្សាំនៅសហគមន៍ ដែលបានទទួលការគាំទ្រពីមូលនិធិបរិស្ថានពិភពលោក (GEF) បានចាប់ផ្តើមតម្លើងប្រព័ន្ធបំពង់ទឹកនៅឆ្នាំ ២០០៧ ដោយបានចែកចាយទឹកពីចំណុចទឹកធ្លាក់មួយកន្លែងនៅជិតនោះ ដល់ប្រជាជនចំនួន ៣០០គ្រួសារ នៅក្នុងភូមិចំនួនបី។ យូអិនឌីភីបានធ្វើការជាមួយសហគមន៍មូលដ្ឋាន ដើម្បីតម្លើងប្រព័ន្ធបំពង់ចែកចាយទឹកប្រវែង ២៥គ.ម ដោយផ្តល់ទឹកគ្រប់រដូវ ដែលជាការកែលម្អសេវាអនាម័យ ដូចជា បង្គន់អនាម័យដែលជាប្រណិតភាពពុំធ្លាប់ឮពីមុនមក និងទើបតែមាននៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះប៉ុណ្ណោះ។ ជាមួយមូលនិធិបន្ថែមពីប្រទេសស៊ុយអែដ ការពង្រីកបណ្តាញបំពង់ចែកចាយទឹក ត្រូវបានអនុវត្តរួចរាល់ដើម្បីផ្តល់ទឹកដល់ភូមិចំនួនបីបន្ថែមទៀត។

បណ្តាញចែកចាយទឹកក៏បានកាត់បន្ថយបន្ទុកយ៉ាងច្រើនរបស់ស្ត្រីក្នុងការដងទឹកប្រចាំថ្ងៃផងដែរ ដូចជា អ៊ូ សុឃីម ជាស្ត្រីដែលមានកូនពីរនាក់។ គាត់បានពោលថា “កាលដែលខ្វះទឹក ជីវិតរស់នៅលំបាកខ្លាំងណាស់។ ដំណាំតែងតែងាប់ ហើយកូនមានជម្ងឺរាករូសញឹកញាប់។ តែចាប់តាំងពីយើងមានទឹកស្អាត កូនរបស់ខ្ញុំកម្រឈឺណាស់ ដោយសារយើងអាចងូត និងសំអាតខ្លួនបានញឹកញាប់ ហើយដល់អញ្ចឹងពួកវាអាចទៅរៀនជាទៀងទាត់”។

មានទឹកអាចអនុញ្ញាតឲ្យភូមិនានាដាំបន្លែ និងផ្លែឈើសរីរាង្គនៅក្នុងច្បារដំណាំផ្ទាល់ខ្លួន និងលក់ទៅមណ្ឌលអេកូទេសចរណ៍ចំបក់ដែលនៅជិតនោះផងដែរ។ ក្នុងពេលដែលសហគមន៍ទាំងមូលចាប់ផ្តើមរីកចម្រើន មណ្ឌលអេកូទេសចរណ៍ក៏បានទទួលជោគជ័យផងដែរ។ កំណើនចំនួនភ្ញៀវទេសចរមកកំសាន្ត មានន័យថា មានតម្រូវការឲ្យផ្លែឈើ និងបន្លែកាន់តែមានគុណភាពខ្ពស់។ ចាប់ពីពេលនោះមកកសិករនៅមូលដ្ឋានដែលបានផលិតលើសពីតម្រូវការក៏ចាប់ទទួលផលចំណេញផងដែរ។

ទូច ម៉ន ប្រធានមជ្ឈមណ្ឌលអេកូទេសចរណ៍ចំបក់ បានរម្លឹកពីការដែលបុគ្គលិករបស់គាត់ត្រូវទិញបន្លែពីទីផ្សារនៅឆ្ងាយ ដើម្បីបម្រើភ្ញៀវទេសចរនៅមជ្ឈមណ្ឌលនេះ។ នៅពេលនេះ ពួកគេអាចទទួលបានបន្លែស្រស់ៗដោយផ្ទាល់ពីអ្នកភូមិ។

ទូច ម៉ន បានពោលថា “ឥឡូវនេះដំណើរការក្នុងភោជនីយដ្ឋាននេះមានភាពងាយស្រួលណាស់ ដោយសារយើងអាចទទួលបានរបស់គ្រប់យ៉ាងដែលយើងត្រូវការចាំបាច់ ពីទីជិតៗក្នុងមូលដ្ឋាននេះតែម្តង”។

នៅទីនេះ យើងក៏ទទួលបានផលប្រយោជន៍ខាងបរិស្ថានផងដែរ។ អ្នកភូមិជាច្រើនធ្លាប់តែពឹងផ្អែកលើការបរបាញ់សត្វព្រៃ និងកាប់ដើមឈើដើម្បីទ្រទ្រង់របរចិញ្ចឹមជីវិត ដែលធ្វើឲ្យខូចខាតប្រព័ន្ធអេកូឡូស៊ី។ ទូច ម៉ន ធ្លាប់ជាមនុស្សម្នាក់ក្នុងចំណោមអ្នកទាំងនោះផងដែរ ប៉ុន្តែបច្ចុប្បន្ននេះ គាត់គឺជាអ្នកដែលធ្វើការដើម្បីបរិស្ថានជាមួយមិត្តភក្តិនៅក្នុងភូមិ ដើម្បីថែរក្សាព្រៃឈើ លើភ្នំជុំវិញភូមិនេះ។

នៅពេលដែលប្រព័ន្ធចែកចាយទឹកកំពុងរៀបចំតម្លើង អ្នកមូលដ្ឋានរំពឹងថា ពួកគេមានត្រឹមតែទឹកគ្រប់គ្រាន់សម្រាប់ផឹក និងបោកគក់ប៉ុណ្ណោះ។ ទូច ម៉ន បានពោលរម្លឹកអំពីគម្រោងនេះថា “ប៉ុន្តែឥឡូវនេះ ពួកគេអាចប្រើប្រាស់ទឹកសម្រាប់ដាំបន្លែនៅក្នុងច្បាររបស់ពួកគេ ដើម្បីទទួលបានប្រាក់បន្ថែម” ហើយគាត់ចាត់ទុកថា គម្រោងនេះជា “សមិទ្ធផលប្រវត្តិសាស្ត្រ” ក្នុងការលើកកំពស់ការរស់នៅរបស់អ្នកភូមិនៅឃុំចំបក់នេះ តែម្តង។

## ពីចម្ការមីន...

*តមកពីទំព័រទី ១*



PHOTO: UNDP Cambodia

*អ្នកស្រី ឃិត សារិន ឥឡូវនេះអាចដាំដំណាំនៅលើដីក្រោយផ្ទះបន្ទាប់ពីវាត្រូវបានបោសសម្អាតគ្រាប់មីនរួច។*

ដោយចែដន្យដែលធ្វើឲ្យផ្ទុះក្នុងចម្ងាយប្រមាណ ១០០ម ពីផ្ទះគាត់។ គាត់ពោលថា“ខ្ញុំខ្លាចណាស់ ប៉ុន្តែខ្ញុំចង់ដឹងថាមានអ្វីកើតឡើង។ ខ្ញុំនៅចាំថាខ្ញុំធ្លាប់ដើរនៅកន្លែងផ្ទុះនោះ ដើម្បីរើសបំណែកដែកទុកលក់□។

ដូចអ្នកស្រី ឃិត សារិនដែរ កាលពីមុន លោក នូ ជាតាមិនអាចប្រើប្រាស់ដីក្រោយផ្ទះបានច្រើនឡើយ ដោយបារម្ភខ្លាចជាន់គ្រាប់មីន។ ក្រោយពីបានដោះមីនអស់មក គាត់បានដាំឈើហូបផ្លែលើដីទំហំ ១០ម x ១០០ម។ គាត់សង្ឃឹមថា ផលចំណេញពីនេះនឹងបន្ថែមលើប្រាក់ចំណូលប្រចាំឆ្នាំរបស់គាត់ដែលមានស្ទើរមិនដល់ចំនួន ១.០០០ដុល្លា ផងនោះ។

តាមរយៈគម្រោង “សម្អាតដើម្បីលទ្ធផល” យូអិនឌីភីបាននិងកំពុងធ្វើជាដៃគូជាមួយអាជ្ញាធរសកម្មភាពមីន និងជួយជនរងគ្រោះកម្ពុជា (CMAA) នៅក្នុងការចាត់ចែងនិយ័តកម្ម តាមដាន និងគ្រប់គ្រងវិស័យសកម្មភាពមីន។ គម្រោងដែលមានទឹកប្រាក់ចំនួន ២៥លានដុល្លា ដែលគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី ស្វីស កាណាដា និងប្រទេសដទៃទៀត មានគោលដៅជម្រុញការរំដោះដីពីគ្រាប់មីនសម្រាប់សហគមន៍ទន់ខ្សោយភាគច្រើន ដើម្បីប្រើប្រាស់ក្នុងកសិកម្ម។

គម្រោង “សម្អាតដើម្បីលទ្ធផល” ដែលឥឡូវនេះស្ថិតក្នុងដំណាក់កាលទី ២ ឆ្នាំ ២០១៣-២០១៤ បានជួយរំដោះដីទំហំ ៣.៨០៦.៨៣៣ម២ ក្នុងខេត្តប៉ៃលិន។ ជាសរុប គម្រោងនេះបានរំដោះដីធំជាង ៥១គ.ម$^{២}$ នៅក្នុងបណ្តាខេត្តដែលមានគ្រាប់មីនបង្កប់ក្នុងដីច្រើនជាងគេដែលរួមទាំងខេត្តប៉ៃលិន បាត់ដំបងនិងបន្ទាយមានជ័យ គិតចាប់តាំងពីការបោសសំអាតបានចាប់ផ្តើមនៅក្នុងឆ្នាំ ២០១១មក។ លើសពីនេះ គម្រោងនេះបានរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ដោយសារគ្រាប់មីននៅក្នុងខេត្តគោលដៅទាំងបី ចាប់ពី ៦៨នាក់ក្នុងឆ្នាំ ២០១១ មកត្រឹម ១១នាក់ នៅឆ្នាំ ២០១៣។

អ្នកស្រី ឃិត សារិនបានពោលថា “ខ្ញុំមានការភ្ញាក់ផ្អើលដោយហេតុថា ខ្ញុំមានសំណាងណាស់ដែលពុំមានគ្រោះថ្នាក់ ឬពិការដៃ ឬជើង។ ឥឡូវនេះ ខ្ញុំមានអារម្មណ៍ថាមានសុវត្ថិភាពនិងមិនព្រួយបារម្ភឡើយនៅពេលជីកដីនិងដាំដំណាំ មិនដូចមុនទៀតឡើយ”។

## នៅឃុំត្រពាំងចាន់...

*តមកពីទំព័រទី ១*

ឡូវថ្មីដែលលក់ក្នុងតម្លៃ ១-២ដុល្លា ក្នុងមួយឯកត្តា អាចផ្តល់ផលចំណេញប្រមាណ ៧០០-១.០០០ រៀល (០,១៧-០,២៥ដុល្លាអាមេរិក) ក្នុងចង្ក្រានមួយៗ។ នៅឆ្នាំ ២០១៣ អ្នកផលិតលក់ចង្ក្រានបែបនេះបាន ៣៥.៥៤១ ឯកត្តា ដែលបានផ្តល់ប្រាក់ចំណូលសរុបចំនួន ១៤.៤០៧ដុល្លាអាមេរិក។

សុគន្ធ ធីតា អាយុ ២៥ឆ្នាំ និងជាស្ត្រីដែលមានកូនពីរនាក់ បានចាប់ផ្តើមផលិតចង្ក្រាននៅខែមេសាឆ្នាំនេះ។ អ្នកស្រីពោលថា “ខ្ញុំអាចលក់ចង្ក្រានជាមធ្យមអស់ ២០០ គ្រឿងក្នុងមួយខែ។ គាត់បន្ថែមថា “បើខ្ញុំមានអ្នកជួយម្នាក់ខ្ញុំអាចរកបានចំណូល ១ដុល្លា ក្នុងចង្ក្រានមួយដែលខ្ញុំលក់ដាច់។”

ការផលិតចង្ក្រានប្រសិទ្ធភាពថាមពល បានបង្កើតការងារថ្មីចំនួន ១១៨កន្លែង នៅឆ្នាំ២០១៣ ដែលរួមមានសម្រាប់ផលិតករ សិប្បករ និងអ្នកលក់រាយក្នុងនោះ ៩៤នាក់ គឺជាស្ត្រី។ អ្នកផលិត និងអ្នកចែកចាយ ប្រើប្រាស់ផលចំណេញសម្រាប់បំពេញតម្រូវការចាំបាច់របស់ខ្លួនដូចជា ដើម្បីទិញចំណីអាហារ និងសងបំណុលពីការទិញសម្ភារៈ និងការសាងសង់ទីកន្លែងផលិត។ ក្នុងឆ្នាំដដែលនេះ ការបំភាយឧស្ម័នកាបូនិកអាចកាត់បន្ថយបានប្រមាណ២.៦៨០ឯកកត្តាតាមរយៈការប្រើប្រាស់ចង្ក្រានប្រសិទ្ធភាពថាមពល។

# សន្ទស្សន៍អភិវឌ្ឍន៍មនុស្សកម្ពុជាបន្តកើនឡើង

នៅខែ កក្កដា កន្លងទៅនេះ យូអិនឌីភី បានប្រកាសផ្សាយរបាយការណ៍អភិវឌ្ឍន៍មនុស្ស (HDR) ពិភពលោក ឆ្នាំ ២០១៤ នៅតូក្យូ ដោយផ្តោតលើការកាត់បន្ថយភាពងាយរងគ្រោះ និងកសាងភាពធន់។ តួលេខសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (Human Development Index/HDI) សម្រាប់កម្ពុជានៅឆ្នាំ២០១៣ គឺ ០,៥៨៤ ដែលស្ថិតក្នុងលំដាប់នៃការអភិវឌ្ឍមនុស្សកំរិតកណ្តាល និងដាក់កម្ពុជាក្នុងចំណាត់ថ្នាក់ទី១៣៦ ក្នុងចំណោមប្រទេស និងដែនដីចំនួនសរុប ១៨៧។

នៅរវាងឆ្នាំ១៩៨០ និង ២០១៣ តួលេខសន្ទស្សន៍អភិវឌ្ឍន៍មនុស្សកម្ពុជា បានកើនឡើងពី ០,២៥១ ដល់ ០,៥៨៤ ដែលជាកំណើន ១៣២,៧% ឬ កំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ ២,៥៩%។ នេះមានន័យថា កម្ពុជាបន្តឈានឡើង ដោយមានការប្រែប្រួលវិជ្ជមានលើទិដ្ឋភាពទាំងបី ពោលគឺ អាយុកាល ការអប់រំ និងចំណូលដុលរបស់ជាតិ (GNI) គិតក្នុងម្នាក់ៗ គិតចាប់ពីឆ្នាំ ១៩៨០ ដល់ ២០១៣។ ប្រទេសប៊ុយតង់ ក៏មានចំណាត់ថ្នាក់ថ្មីលេខ ១៣៦ នេះដែរ។

នៅឆ្នាំ ២០១០ របាយការណ៍អភិវឌ្ឍន៍មនុស្ស (HDR) បានដាក់បញ្ចូលសន្ទស្សន៍ថ្មីៗ ដែលផ្តល់ការវិភាគបានកាន់តែសុក្រិត្យជាងមុននូវសមិទ្ធផលនៃការអភិវឌ្ឍក្នុងប្រទេសនីមួយៗ។ សន្ទស្សន៍ដែលបានកែតម្រូវតាមវិសមភាព (IHDI) បានគិតបញ្ចូលវិសមភាព ឬ "ការបាតបង់" ការអភិវឌ្ឍមនុស្សបណ្តាលពីវិសមភាពលើទិដ្ឋភាពបីដែលត្រូវបានយកមកគណនា។ តួលេខសន្ទស្សន៍អភិវឌ្ឍន៍មនុស្សកម្ពុជាគឺ ០,៥៨៤ ប៉ុន្តែបានធ្លាក់ចុះមកត្រឹម ០,៤៤០ ប្រសិនបើគិតបញ្ចូលវិសមភាព។

បន្ថែមលើនេះ សន្ទស្សន៍វិសមភាពយេនឌ័រ (GII) ឆ្លុះបញ្ចាំងវិសមភាពខាងយេនឌ័រនៅក្នុងទិដ្ឋភាពទាំងបី ពោលគឺ សុខភាពបន្តពូជ ការពង្រឹងភាពអង់អាច និងសកម្មភាពសេដ្ឋកិច្ច។ សុខភាពបន្តពូជ ត្រូវបានវាស់តាមរយៈអត្រាមរណភាពមាតា និងអត្រាកំណើតនៃក្មេងជំទង់, ការពង្រឹងភាពអង់អាច ដែលវាស់ដោយផលធៀបនៃអាសនៈនៅក្នុងសភាដែលកាន់កាប់ដោយស្ត្រី និងការទទួលបានការសិក្សានៅកម្រិតមធ្យម និងឧត្តមសិក្សាសម្រាប់ភេទទាំងពីរ, និងសកម្មភាពសេដ្ឋកិច្ច ដែលវាស់ដោយអត្រាចូលរួមក្នុងទីផ្សារការងារសម្រាប់ស្ត្រី និងបុរស។ សន្ទស្សន៍វិសមភាពយេនឌ័រ GII អាចបកស្រាយបានថាជាការបាត់បង់ខាងការអភិវឌ្ឍមនុស្ស ដោយសារវិសមភាពរវាងសមិទ្ធផលសម្រាប់ស្ត្រី និងបុរសនៅក្នុងទិដ្ឋភាពទាំងបីនៃ ។

កម្ពុជាមានតួលេខ GII ស្មើ ០,៥០៥ ដែលស្ថិតក្នុងលំដាប់ទី ១០៥ ក្នុងចំណោមប្រទេសទាំងអស់ចំនួន ១៤៩ នៅក្នុងសន្ទស្សន៍ឆ្នាំ ២០១៣។ នៅកម្ពុជាស្ត្រីកាន់កាប់អាសនៈចំនួន ១៨,១% នៅក្នុងសភា ហើយស្ត្រីវ័យកណ្តាលចំនួន៩,៩%សម្រេចបានយ៉ាងហោចណាស់ការសិក្សានៅកម្រិតមធ្យមសិក្សា ធៀបនឹង ២២,២% សម្រាប់បុរស។ ក្នុង ១០០.០០០កំណើតរស់ ស្ត្រី ២៥០ នាក់បានបាត់បង់ជីវិត ដោយសារតែមូលហេតុដែលទាក់ទងនឹងការមានផ្ទៃពោះ ហើយអត្រាកំណើតនៃក្មេងជំទង់គឺ ៤៤,៣ ក្នុងកំណើតរស់ ១.០០០។ ការចូលរួមរបស់ស្ត្រីនៅក្នុងទីផ្សារការងារគឺ ៧៨,៩% ធៀបនឹងបុរស ៨៦,៥%។

នៅឆ្នាំ ២០១៤ របាយការណ៍អភិវឌ្ឍន៍មនុស្សបានបញ្ចូលសន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ (GDI) ដោយផ្អែកលើសន្ទស្សន៍អភិវឌ្ឍន៍មនុស្សដែលញែកដាច់គ្នាតាមយេនឌ័រ ដោយកំណត់អំពីផលធៀបនៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្សរវាងបុរស និងស្ត្រី។ សន្ទស្សន៍ GDI វាស់វិសមភាពយេនឌ័រលើសមិទ្ធផលសំខាន់ៗចំនួនបី នៃការអភិវឌ្ឍមនុស្ស ពោលគឺ សុខភាព (ដែលវាស់ដោយអាយុកាលរបស់ស្ត្រី និងបុរសនៅពេលកើត) ការអប់រំ (វាស់ដោយចំនួនឆ្នាំរំពឹងទុកនៃការចូលរួមរបស់កុមារានិងកុមារី និងចំនួនឆ្នាំជាមធ្យមសម្រាប់មនុស្សវ័យកណ្តាលដែលមានអាយុ ២៥ឆ្នាំឡើង) និងអំណាចត្រួតត្រាលើធនធានសេដ្ឋកិច្ច (វាស់ដោយសន្ទស្សន៍ GNI សម្រាប់ស្ត្រី និងបុរសក្នុងម្នាក់ៗ)។ តួលេខសន្ទស្សន៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជាសម្រាប់ស្ត្រីក្នុងឆ្នាំ ២០១៣ គឺ ០,៥៣៣ និងសម្រាប់បុរសគឺ០,៥៨៧ដែលនាំឲ្យមានតួលេខសន្ទស្សន៍ GDI ស្មើ ០,៩០៩។

## សូចនាករអភិវឌ្ឍន៍មនុស្សកម្ពុជា ដែលបានវាស់នៅឆ្នាំ ២០១៣ មានដូចតទៅ៖

| សន្ទស្សន៍ | តួលេខ |
|---|---|
| **សុខភាព** អាយុកាលនៅពេលកើត | ៧១,៩២ |
| **ការអប់រំ** ចំនួនឆ្នាំសិក្សាជាមធ្យម | ៥,៧៧ |
| **ប្រាក់ចំណូល/លទ្ធភាពគ្រប់គ្រងធនធាន**<br>ចំណូលដុលរបស់ជាតិ (GNI) ក្នុងម្នាក់ៗ (2011 PPP $) | ២.៨០៥,៤៣ |
| **វិសមភាព** សន្ទស្សន៍វិសមភាពយេនឌ័រ | ០,៥០៥ |
| **ភាពក្រីក្រ** ចំនួនប្រជាជនដែលមានភាពក្រីក្រពហុទិដ្ឋភាព (%) | ៤៦,៧៩ |
| **ភាពមានការងារធ្វើនិងភាពងាយរងគ្រោះ**<br>អត្រាអ្នកមានការងារធ្វើធៀបនឹងចំនួនប្រជាជនសរុប | ៨៥,៨ |
| **សន្តិសុខមនុស្ស** ចំនួនប្រជាជនដែលគ្មានផ្ទះសំបែង (%នៃចំនួនប្រជាជនសរុប) | ២,២២៥ |
| **លំហូរពាណិជ្ជកម្ម និងហិរញ្ញវត្ថុ** ពាណិជ្ជកម្មអន្តរជាតិ (%នៃ GDP) | ១១៣,៥៨ |
| **ភាពចល័ត និងការប្រាស្រ័យទាក់ទង**<br>អត្រាចំណាកស្រុកពិត (ក្នុងប្រជាជន ១០០០នាក់) | -២,៣ |
| **បរិស្ថាន** ការបំភាយឧស្ម័នកាបូនិកក្នុងម្នាក់ៗ (តោន) | ០,២៩ |
| **ប្រជាសាស្ត្រ** ចំនួនប្រជាជនសរុប (លាននាក់) | ១៥,១៤ |

*សេចក្តីពិស្តារអំពីរបាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ ២០១៤ មាននៅក្នុង http://hdr.undp.org/en.*

## កិច្ចគាំពារសង្គមជាគន្លឹះក្នុងការកាត់បន្ថយភាពងាយរងគ្រោះនៃជនក្រីក្រ

មន្ត្រីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានពោលនៅក្នុងពិធីមួយក្នុងពេលថ្មីៗនេះ ដើម្បីផ្សព្វផ្សាយរបាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ ២០១៤ ថាភាពក្រីក្រត្រូវបានកាត់បន្ថយយ៉ាងច្រើននៅកម្ពុជា ប៉ុន្តែប្រទេសនេះត្រូវតែបន្តធ្វើការពង្រឹងប្រព័ន្ធគាំពារសង្គមដើម្បីទប់ស្កាត់និន្នាការនេះកុំឲ្យប្រាសថយក្រោយមកវិញ។

ឯកឧត្តម ងី ច័ន្ទផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងជនបទនៃកម្ពុជា មានប្រសាសន៍ថា "យើងត្រូវតែពង្រឹងពង្រីកវិសាលភាពនៃកិច្ចគាំពារសង្គមថែមទៀត ដើម្បីជួយកាត់បន្ថយហានិភ័យ ដែលមានចំពោះជនក្រីក្រ ក៏ដូចជា ដើម្បីបង្កើនភាពធន់របស់អ្នកទាំងនោះ ដើម្បីទប់ទល់ចំពោះហានិភ័យទាំងនោះផងដែរ ។"ឯកឧត្តមបានពោលទៀតថា "យើងមិនអាចពេញចិត្តត្រឹមតែចំពោះអ្វីដែល សម្រេចបានមកទល់បច្ចុប្បន្នប៉ុណ្ណោះទេ"។

ឯកឧត្តមពោលនៅក្នុងសិក្ខាសាលាមួយ ដើម្បីផ្សព្វផ្សាយរបាយការណ៍នេះ កាលពីថ្ងៃទី ២ ខែកញ្ញា ដែលមានចំណងជើងថា "ទ្រទ្រង់វឌ្ឍនភាព៖ កាត់បន្ថយភាពងាយរងគ្រោះ និងកសាងភាពធន់"។ ពិធីនេះបានចាត់ចែងឡើងដោយ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយក្រោមការគាំទ្រពីយូអិនឌីភីនៅកម្ពុជា។ ប្រធានបទនៃរបាយការណ៍នេះមានការពាក់ព័ន្ធបំផុតសម្រាប់កម្ពុជា ដែលនៅតែត្រូវបានចាត់ទុកថាងាយរងគ្រោះបំផុតនៅចំពោះមុខហានិភ័យមួយចំនួន បើទោះជាបានធ្វើឲ្យមានវឌ្ឍនភាពលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ខ្លួនហើយក៏ដោយនៅក្នុងពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ ។

ទោះបីកម្រិតនៃភាពក្រីក្រឥឡូវនេះបានថយចុះមកត្រឹម១៩,៨%ក៏ដោយ ប្រជាជនកម្ពុជាយ៉ាងច្រើនកំពុងរស់នៅសំកាំង ពីលើខ្សែបន្ទាត់ភាពក្រីក្រ ៣.៨៧១ រៀល (០,៩៦ដុល្លាអាមេរិក)ក្នុងមួយថ្ងៃ ដែលធ្វើឲ្យពួកគេងាយធ្លាក់ចុះមកក្នុងភាពក្រីក្រវិញ ក្នុងករណីមានការប៉ះទង្គិចនានា ដូចជា វិបត្តិសេដ្ឋកិច្ច ឬគ្រោះមហន្តរាយធម្មជាតិ។

នាយករងយូអិនឌីភីនៅកម្ពុជា លោក ណាប៉ូឡេអុង ណាវ៉ារ៉ូ បានពោលថា "កម្ពុជាបានធ្វើឲ្យមានកំណើនយ៉ាងច្រើនហើយប្រសិនបើចង់ការពារកំណើនទាំងនេះ គេត្រូវដោះស្រាយភាពងាយរងគ្រោះ"។

ឯកឧត្តម ងី ច័ន្ទផល បានឯកភាពដោយពោលថា "ការឈានទៅរកការអភិវឌ្ឍរបស់យើង គឺជាដំណើរដ៏វែងឆ្ងាយប្រកបដោយការលំបាក ប៉ុន្តែនៅពីមុខយើងនៅមានការប្រឈមជាច្រើននៅឡើយ ដែលយើងត្រូវបន្តដោះស្រាយ"។

# បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការនៅមូលដ្ឋាន

កម្ពុជាបានចាប់ផ្តើមជំហានមួយសំខាន់ ឆ្ពោះទៅរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការ និងថវិកាថ្នាក់ក្រោមជាតិ។វាជាចំណាត់ការដែលត្រូវបានធ្វើឡើងនៅចំពេលដែលចំនួនពាក់កណ្តាលនៃឃុំនៅកម្ពុជា ត្រូវបានគេចាត់ទុកថាស្ថិតក្នុងស្ថានភាពងាយរងគ្រោះ និងងាយរងគ្រោះបំផុត ដោយសារតែអថេរអាកាសធាតុ ដូចដែលអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) បានរាយការណ៍ឲ្យដឹងកាលពី ពេលថ្មីៗនេះ។

តាមរយៈគម្រោងពង្រីកសកម្មភាពរបស់ យូអិនឌីភី គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅ ថ្នាក់ក្រោមជាតិ (NCDD) បានបង្កើតគោលការណ៍ណែនាំសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ដែលត្រូវ អនុវត្តនៅថ្នាក់ស្រុក និងឃុំ នៅទូទាំងប្រទេសក្នុងពេលអនាគត។ ការរៀបចំគោលការណ៍ណែនាំនេះបានអនុវត្តតាមសកម្មភាពសាកល្បងក្នុងខេត្តមួយចំនួន។ ក្រៅពីគោលការណ៍ណែនាំសម្រាប់ការបញ្ជ្រាបលទ្ធផលគន្លឹះនានានៃគម្រោងនោះ រួមមាន ជំនាញ និងយន្តការនានាដែលនឹងផ្តល់ជាគំរូសម្រាប់រដ្ឋាភិបាលថ្នាក់មូលដ្ឋាន ដើម្បីរៀបចំនិងអនុវត្ត យុទ្ធសាស្ត្រ និងគម្រោងធន់នឹងអាកាសធាតុ។ យន្តការហិរញ្ញប្បទានមួយក៏នឹងត្រូវបង្កើតឡើងផងដែរ ដើម្បីឲ្យមានការឆ្លើយតបប្រកបដោយសង្គតិភាពទៅនឹងការប្រែប្រួលអាកាសធាតុ។

ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការនៅថ្នាក់ក្រោមជាតិ និងដំណើរការលើកថវិកាមានការពាក់ព័ន្ធជាមួយការចងក្រងជាឯកសារនូវទម្លាប់អនុវត្តល្អៗ និងមេរៀននានាដែលបានពីការអនុវត្តកិច្ចផ្តួចផ្តើមដែលធន់នឹងអាកាសធាតុដែលធ្វើឡើងដោយសហគមន៍ និងការពង្រីកកិច្ចផ្តួចផ្តើមទាំងនោះពីទីកន្លែងមួយទៅកន្លែងផ្សេងទៀត។

មេរៀនមួយក្នុងចំណោមមេរៀននានាដែលទទួលបាន គឺ ការរួមបញ្ចូលបច្ចេកទេសធន់នឹងអាកាសធាតុទៅក្នុងការជួសជុលផ្លូវថ្នល់។ នៅក្នុងខេត្តបាត់ដំបង ផ្លូវថ្នល់ប្រវែងជាង ២គ.ម ដែលលាតសន្ធឹងកាត់ឃុំមួយចំនួនក្នុងស្រុកឯកភ្នំ បានរងការជន់លិចជារៀងរាល់ឆ្នាំ ដែលរាំងការធ្វើចរាចរ និងការដឹកទំនិញទៅមកពីទីក្រុងនានា។ នៅរដូវប្រាំង ផ្លូវនេះត្រូវបានជួសជុល ប៉ុន្តែត្រូវខូចខាតឡើងវិញ នៅពេលដែលទឹកស្ទឹងជោរជន់នៅក្នុងរដូវវស្សា និងលិចផ្លូវថ្នល់។

នៅឆ្នាំ២០១៣ យូអិនឌីភីបានសាកល្បងបច្ចេកទេសធន់នឹងអាកាសធាតុនៅក្នុងការងារជួសជុលនេះ។ លោក សេង យី ប្រធានឃុំសឹង នៃស្រុកឯកភ្នំ ដែលជាកន្លែងអនុវត្តសាកល្បងគម្រោងនេះ បានពោលថា “ការកែលម្អផ្លូវបាននាំមកនូវអត្ថប្រយោជន៍ជាច្រើនដល់ប្រជាជននៅតាមឃុំដែលជាប់នឹងផ្លូវនេះ”។

ការពង្រីកសកម្មភាពនេះ ពាក់ព័ន្ធជាមួយដំណើរការដែលមានបីជំហានដែលរួមទាំង ១) ការវាយតម្លៃហានិភ័យនៃភាពងាយរងគ្រោះ (VRA); ២) ការកសាងផែនការ និងការកំណត់បញ្ហា និង ៣) ការចាត់ជាអាទិភាព និងការវិនិយោគលើផែនការនានា។ គម្រោងនេះកំពុងស្ថិតក្នុងការអនុវត្តនៅក្នុងស្រុកចំនួនប្រាំនៃខេត្តចំនួនបី ពោលគឺ ខេត្តតាកែវ បាត់ដំបង និងព្រះវិហារ។ ការចាត់ជាអាទិភាព និងការវិភាគសម្រាប់វិនិយោគ លើគម្រោងដែលធន់នឹងអាកាសធាតុ ត្រូវបានអនុវត្តរួចរាល់នៅក្នុងស្រុកគោលដៅទាំងប្រាំ នៃខេត្តសាកល្បងចំនួនបី។

បច្ចុប្បន្ននេះ យូអិនឌីភី កំពុងជួយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីរៀបចំគោលការណ៍ណែនាំសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងឯកសារណែនាំបច្ចេកទេសក្រោមការពិគ្រោះយោបល់ជាមួយក្រសួងនានា និងដៃគូអភិវឌ្ឍន៍។

លោក ណាប៉ូឡេអុង ណាវ៉ារ៉ូ នាយករងយូអិនឌីភីប្រចាំនៅកម្ពុជា បានពោលថា “នេះជាជំហានសំខាន់មួយដើម្បីលើកកំពស់ភាពម្ចាស់ការនៅមូលដ្ឋាន ជាពិសេសតួនាទីរបស់ស្រុក និងឃុំ ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការនៅមូលដ្ឋាន ក្នុងការឆ្លើយតបនឹងផលវិបាកនានានៃការប្រែប្រួលអាកាសធាតុ។ ”លោកបានបន្ថែមថា “ការកសាងផែនការឲ្យប្រសើរជាងមុន និងការវិនិយោគលើការអភិវឌ្ឍ គឺជាជម្រើសប្រសើរបំផុតដើម្បីជួយសហគមន៍ជនបទឲ្យចៀសផុតពីការប៉ះទង្គិចដោយផ្ទាល់ពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ។”

ក្រុមស្នូលមួយត្រូវបានបង្កើតឡើងជាផ្លូវការនៅក្រោមការដឹកនាំនៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្រុមនេះមានសមាសភាពមកពីក្រសួងបរិស្ថាន ផែនការ មហាផ្ទៃ ហិរញ្ញវត្ថុ និងកសិកម្ម និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក៏ដូចជា ដៃគូអភិវឌ្ឍន៍ផងដែរ ដែលរួមទាំង ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែដ សហភាពអឺរ៉ុប យូអិនឌីភី មូលនិធិអភិវឌ្ឍន៍មូលធននៃអង្គការសហប្រជាជាតិធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក។

# អ្នកស្ម័គ្រចិត្តសហប្រជាជាតិរៀបចំវេទិកាជាតិ លើកទី ៤ ស្តីពីភាពជាអ្នកស្ម័គ្រចិត្ត

អ្នកស្ម័គ្រចិត្តសហប្រជាជាតិនៅកម្ពុជា (UNV) រួមជាមួយក្រសួងអប់រំ យុវជន និងកីឡា និងបណ្តាញស្ម័គ្រចិត្តកម្ពុជា បានរៀបចំដោយជោគជ័យវេទិកាជាតិលើកទី៤ស្តីពីភាពជាអ្នកស្ម័គ្រចិត្ត ក្រោមចំណងជើងថា “ធ្វើជាមនុស្សគំរូ ធ្វើជាអ្នកស្ម័គ្រចិត្ត” ដើម្បីបង្កើនការយល់ដឹងអំពីឥទ្ធិពលដែលអ្នកស្ម័គ្រចិត្តបានធ្វើជាវិភាគទានទៅក្នុងការអភិវឌ្ឍកម្ពុជា។

ពិធីនេះដែលបានរៀបចំឡើងនៅថ្ងៃទី ១០ ខែកញ្ញា នៅវិទ្យាស្ថានជាតិអប់រំ ក្នុងក្រុងភ្នំពេញ មានការចូលរួមនៃយុវជនកម្ពុជាច្រើនជាង ៦០០នាក់ មកពីសកលវិទ្យាល័យ សង្គមស៊ីវិល អង្គការអ្នកស្ម័គ្រចិត្ត និងវិស័យឯកជន។

លោកស្រី ក្លែរ វ៉ាន់ ដឺ វ៉ារេន អ្នកសម្របសម្រួលអង្គការសហប្រជាជាតិនៅកម្ពុជា បានថ្លែងនៅក្នុងសុន្ទរកថាបើកពិធីនេះថា “តាមរយៈវិភាគទានជាពេលវេលា និងជំនាញ ជាពិសេស នៅក្នុងវិស័យសង្គមកិច្ច ភាពជាអ្នកស្ម័គ្រចិត្ត បានដើរតួប្រកបដោយអត្ថន័យនៅក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។” លោកស្រីបានបន្ថែមថា “ភាពជាអ្នកស្ម័គ្រចិត្តគឺជាវិធីមួយដើម្បីកសាងជំនាញ និងការទទួលខុសត្រូវសង្គមរបស់ពលរដ្ឋវ័យក្មេង។ ផ្ទុយទៅវិញ នៅពេលដែលអ្នក ខ្ញុំ ក្លាយជាជនស្ម័គ្រចិត្ត សកម្មភាពនេះអាចឲ្យយើងចូលរួមនៅក្នុងការកែលម្អអនាគតនៃសហគមន៍របស់យើង និងបង្កើនការចូលរួមរបស់យើងនៅក្នុងដំណើរការនេះ”។

នៅក្នុងវេទិកានេះ អ្នកស្ម័គ្រចិត្តសហប្រជាជាតិបានប្រកាសជាផ្លូវការនូវក្បួនដំណើរនៃអ្នកស្ម័គ្រចិត្ត ដែលផ្តល់ជាមាគ៌ាមួយសម្រាប់ការផ្សព្វផ្សាយព័ត៌មានអំពីឱកាសធ្វើជាអ្នកស្ម័គ្រចិត្ត ការកសាងបណ្តាញគាំទ្រជាមួយអង្គការអ្នកស្ម័គ្រចិត្ត និងបង្កើតឱកាសសម្រាប់ការពិភាក្សាជាមួយសហគមន៍មូលដ្ឋាន។ កម្មវិធីនេះត្រូវបានអនុវត្តសាកល្បងជាដំបូង នៅក្នុងខេត្តបាត់ដំបង កាលពីខែមិថុនា ពិធីនេះនឹងត្រូវបន្តអនុវត្តនៅក្នុងខេត្តនានាដទៃទៀតក្នុងបណ្តាខែខាងមុខនេះ។

ហូវ សុទ្ធា ក្នុងអាយុ ២២ឆ្នាំ ជានិស្សិតរដ្ឋបាលធុរកិច្ចមកពីសកលវិទ្យាល័យបញ្ញាសាស្ត្រ ដែលបានចូលរួមនៅក្នុងវេទិកានេះ បានធ្វើការឆ្លុះបញ្ចាំងថា “យុវជនមានចំណាប់អារម្មណ៍ច្រើន ហើយឥឡូវនេះ បានផ្តោតលើការធ្វើជាអ្នកស្ម័គ្រចិត្ត។ កម្ពុជាកំពុងអភិវឌ្ឍន៍ ហើយយើងចង់ជួយលើកស្ទួយប្រទេសយើងបន្ថែមទៀត”។

កញ្ញា សុខ អារុណវត្តី ជានិស្សិតអាយុ ២១ឆ្នាំ បានពោលថា “ភាពជាអ្នកស្ម័គ្រចិត្តមានសារៈសំខាន់ណាស់ ដោយសារវាផ្តល់ប្រយោជន៍ដល់អ្នកដែលយើងបានជួយ។ នាងបានបន្ថែមថា “យើងធ្វើការដើម្បីប្រយោជន៍របស់សង្គម”។

វេទិកាជាតិនេះបានធ្វើឡើងជារៀងរាល់ឆ្នាំ ស្របតាមប្រធានបទសកល “នៅក្មេង សកល សកម្ម”។ នៅឆ្នាំ ២០១១ គណៈរដ្ឋមន្ត្រីកម្ពុជា បានអនុម័តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ដែលរួមបញ្ចូលភាពជាអ្នកស្ម័គ្រចិត្តរបស់យុវជន ជាអាទិភាពមួយក្នុងចំណោមអាទិភាពចំនួនបួន។

UNDP
Empowered lives.
Resilient nations.

អគារលេខ ៥៣ វិថី ប៉ាស្ទ័រ សង្កាត់ បឹងកេងកង១
ប្រអប់សំបុត្រលេខ ៨៧៧ ក្រុងភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ +855 (0) 23 216 167
ទូរសារ ៖ +855 (0) 23 216 257
អ៊ីម៉ែល ៖ registry.kh@undp.org
www.kh.undp.org
www.facebook.com/UNDPCambodia
www.twitter.com/UNDPCambodia